ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០២០/២២.........អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង ទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ស្ពឺ"

ព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តកំពង់ស្ពឺ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម យឹម សុខុម ប្រធានក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ**
- **លោក នៅ ឌឹម មេឃុំវល្លិសរ ស្រុកសំរោងទង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្តីផ្តើម

ខេត្តកំពង់ស្ពឺ មានផ្ទៃដីសរុបចំនួន ៦.៩៦៥,៦៣ គីឡូម៉ែត្រការ៉េ ចែកចេញជាក្រុង ចំនួន ០១ មាន ០៥ សង្កាត់ ស្រុកចំនួន ០៧ មាន ៨៣ ឃុំ និងមានភូមិចំនួន ១ ៣៧៩ ភូមិ។ ខេត្តមានប្រជាជនសរុប ចំនួន ៨៧២ ២១៩ នាក់ ក្នុងនោះស្រីចំនួន ៤២៦ ០៥៥ នាក់ គ្រួសារសរុបមានចំនួន ១៨៧ ៨៣៥ គ្រួសារ ដោយក្នុងនោះ វិស័យកសិកម្ម ជាវិស័យចម្បងក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងមានវិស័យសេវាកម្ម និងឧស្សាហកម្ម ដែលជាវិស័យជំរុញដល់កំណើនសេដ្ឋកិច្ចទាំងមូលរបស់ខេត្តឱ្យមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

ដោយសារកំណើនសេដ្ឋកិច្ចមានការកើនឡើង ទើបអត្រានៃភាពក្រីក្រទូទាំងខេត្តត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ពី ១៥.៦% ក្នុងឆ្នាំ ២០១៤ មកនៅត្រឹម ១២.៣% ក្នុងឆ្នាំ ២០១៧ និងមកនៅត្រឹម ១០.៣៩% ក្នុងឆ្នាំ ២០២០។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

- ការងារកសិកម្ម៖ ចំពោះដំណាំស្រូវ ផ្ទៃដីអនុវត្តបាន (រដូវប្រាំង និងរដូវវស្សា) សរុបចំនួន ១២៣ ២២២ ហ.តផ្ទៃដីប្រមូលផល ១២៣ ១៨១ ហ.ត ទិន្នផលមធ្យម ៣,២៨៨ តោន/ហ.ត បរិមាណផលសរុប ៤០៥ ០២៣ តោន និងការងារចិញ្ចឹមសត្វ មានគោសរុបចំនួន ២៧១ ៤២១ ក្បាល កើនឡើងចំនួន ២,៨%, ក្របីចំនួន ៨៩១ ក្បាល ថយចុះចំនួន ៨,៧%, សេះ ចំនួន ០៥ ក្បាល កើនឡើងចំនួន ១០០%, ពពែចំនួន ៩៤៧ ក្បាល កើនឡើងចំនួន ២៩,៥%, ជ្រូកចំនួន ៣២៧ ០៣៤ ក្បាល កើនឡើងចំនួន ១៤,៣%, មាន់ចំនួន ៤ ២៤៩ ៤៥៥ ក្បាល កើនឡើងចំនួន ១៣,៩%, ទាចំនួន ៩៧ ៩៨៨ ក្បាល ថយចុះចំនួន ២៨,១២% និងសត្វស្លាបផ្សេងៗចំនួន ៥ ៨៨៦ ក្បាល កើនឡើងចំនួន ២៦%
- វិស័យការងារ៖ រោងចក្រ សហគ្រាសសរុបទូទាំងខេត្តមានចំនួន ៣៣៤ កន្លែង មានកម្មករ និយោជិត សរុបចំនួន ១៤៤ ៧៩៧ នាក់ ស្រីចំនួន ១០៦ ៩៨២ នាក់ ក្នុងនោះវាយនភ័ណ្ឌ កាត់ដេរ និង ផលិតស្បែកជើងមានចំនួន ១៥១ កន្លែង មានកម្មករ និយោជិតសរុបចំនួន ១៣៩ ៦៧៨ នាក់ ក្នុងនោះស្រីចំនួន ១០៥ ០០១ នាក់
- វិស័យទេសចរណ៍៖ មានតំបន់ទេសចរណ៍ចំនួន ២០ កន្លែង និងអាជីវកម្មសេវាកម្មទេសចរណ៍ សរុបចំនួន ២៨៦ កន្លែង។

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តបានខិតខំបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួនដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- បានរៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ចំនួន ២៨ លើក និងកិច្ចប្រជុំវិសាមញ្ញ ចំនួន ០៧លើក និងបានដាក់ចេញដីកាចំនួន ០១ និងសេចក្តីសម្រេចចំនួន ០៦
- បានរៀបចំផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ (២០២០-២០២៤) និងកម្មវិធីវិនិយោគបីឆ្នាំរំកិលចំនួន ០២ លើក
- បានអនុម័តគាំទ្រការអនុវត្តគម្រោងគុណប្រយោជន៍ខេត្ត និងសកម្មភាព ផអ៣ នៅថ្នាក់ខេត្ត និងនៅមូលដ្ឋាន (ក្រុង ស្រុក និងឃុំ សង្កាត់) តាមរយៈការអភិវឌ្ឍសមត្ថភាពជាប្រចាំដើម្បីផ្តល់ចំណេះដឹង ជំនាញ និងការផ្លាស់ប្តូរឥរិយាបថការងាររបស់បុគ្គលិក ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ

- បានចូលរួមសកម្មភាពជាមួយគណៈអភិបាលខេត្តក្នុងការប្រយុទ្ធ នឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយបានចុះអប់រំផ្សព្វផ្សាយអំពីវិធានការការពារ និងបង្ការការឆ្លងជំងឺកូវីដ-១៩ និងបានចុះចែកអំណោយ និងសម្ភារៈការពារកូវីដ-១៩ ដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ដើម្បីចែកជូនបន្តដល់ប្រជាពលរដ្ឋក្រីក្រក្នុងមូលដ្ឋាន
- បានចូលរួមសកម្មភាពសង្គមតាមរយៈការជួយឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺ និងបានប្រគល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលចំនួន ៩៩ ៥០២ ៥០០ រៀល ជូនដល់គ្រួសារសពដែលបានស្លាប់ដោយសារជំងឺកូវីដ-១៩ ចំនួន ១២៧ នាក់។

❖ **ឃុំវល្លិសរ នៃស្រុកសំពៅងទង**

- ឃុំវល្លិសរ មានផ្ទៃដីសរុប ២.៦៣៣ហិចតា មានភូមិចំនួន ២៣ភូមិ ស្មើនឹងគ្រួសារ៣,៣៨២ គ្រួសារ និងមានប្រជាពលរដ្ឋសរុបចំនួន ១៥,២២៧នាក់ ស្រី ៧,៩៣៤នាក់
- ក្នុងឆ្នាំ២០២០ បានដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋរួចជាស្ថានពរចំនួន ១១៩ករណី
- បានជួសជុលផ្លូវគ្រួសក្រហមចំនួន០៣ខ្សែ ប្រវែងសរុប ៦,៨០០ គ.ម ទីតាំងភូមិចំបក់ ភូមិរកាបាញ់ និងភូមិទួលសំណាង ប្រើប្រាស់ថវិកាមូលនិធិឃុំចំនួន ១០៦.៧៦០.០០០រៀល
- ជួសជុលផ្លូវក្រាលគ្រួសក្រហមបានចំនួន០៥ខ្សែ ប្រវែងសរុប៥,០៣០គ.ម ទីតាំងភូមិពងទឹក ភូមិតាគាំ ភូមិត្បែស ភូមិព្រៃទួល ភូមិព្រៃកោះ ប្រើប្រាស់ថវិកាមូលនិធិឃុំ ចំនួន ១២៨.៧១០.៣០០រៀល
- បានសាងសង់ផ្លូវបេតុងអាមេ ប្រវែង៤៧៨ម៉ែត្រ ទទឹង៦ម៉ែត្រ ទីតាំងភូមិត្បែស ឃុំវល្លិសរ ប្រើប្រាស់ថវិកាមូលនិធិឃុំចំនួន ២៥៣,២២៦,២០០រៀល
- បានផ្តល់សម្ភារៈបង្គន់ អនាម័យ ដល់ប្រជាពលរដ្ឋក្រីក្រចំនួន៣៧គ្រួសារ ឧបត្ថម្ភស្ត្រីក្រីក្រទៅសម្រាលកូននៅមណ្ឌលសុខភាពចំនួន១៤គ្រួសារ
- ក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព រដ្ឋបាលឃុំ បានផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋ ដើម្បីការពារសុវត្ថិភាពភូមិ ឃុំ ដោយបានពង្រឹងកម្លាំងប្រជាការពារ ចំនួន២៤៦នាក់
- បានដាក់ចេញនូវវិធានការបង្ការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រឆាំងការឆ្លងរីករាលដាលនៃវីរុសកូវីដ-១៩ ឆ្លើយតបបានទាន់ពេលវេលានៅតាមបណ្តាមូលដ្ឋានភូមិ សាលារៀន វត្តអារាម មូលដ្ឋានអាជីវកម្ម និងតាមរោងចក្រសហគ្រាស។

### III. ទិសដៅការងារបន្ត

#### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- ពង្រឹងសាមគ្គីភាព និងរបៀបធ្វើការងាររវាងក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត
- ខិតខំអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ស្តីពីការផ្ទេរអំណាច ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព ពិសេសពង្រឹងរដ្ឋបាលឯកភាពក្រុង ស្រុក សំដៅបង្កិតសេវាសាធារណៈឱ្យកាន់តែជិតប្រជាពលរដ្ឋ និងមានប្រសិទ្ធភាព
- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋានដើម្បីប្រមូលតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- បន្តពង្រឹង និងគាំទ្រដល់យន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការិយាល័យប្រជាពលរដ្ឋខេត្ត
- ជំរុញការអនុវត្តនូវគោលការណ៍រដ្ឋបាលឯកភាព និងគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពក្នុងន័យជានាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋឱ្យ បានល្អប្រសើរ
- បន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសបន្តអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឱ្យអនុវត្តវិធានការ ៣កុំ និង ៣ការពារ។

#### ❖ ឃុំវល្លិសរ នៃស្រុកសំពោងទង

- បន្តការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយចំណេះដឹងផ្នែកច្បាប់ ជូនប្រជាពលរដ្ឋ
- បន្តការអនុវត្តហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ពីដីសគ្រួសក្រហម មកជាផ្លូវបេតុង និងផ្លូវកៅស៊ូ
- បន្តការជម្រុញ និងផ្សព្វផ្សាយការងារកសិកម្ម និងបន្លែគ្រប់មុខ ឱ្យបានទិន្នផលខ្ពស់
- បន្តពង្រឹង និងផ្សព្វផ្សាយពីគោលនយោបាយ ភូមិ- ឃុំ មានសុវត្ថិភាពទាំង៧ចំណុច ដើម្បីពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពសង្គមបានកាន់តែល្អប្រសើរដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុង ឃុំ ក៏ដូចជាការរស់នៅរបស់ប្រជាពលរដ្ឋ
- ខិតខំកៀរគរដៃគូ អ្នកវិនិយោគ និងសប្បុរសជនដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន

- បន្តផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងការឆ្លងរីករាលនៃវីរុសកូវីដ-១៩។

## IV. សម្គាល់

តាមរយៈការរបស់រាជរដ្ឋាភិបាល យកចិត្តចំពោះការអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន ជាពិសេសគឺការបង្កើននូវកញ្ចប់ថវិកាអភិវឌ្ឍន៍ ការពង្រឹងសមត្ថភាព និងវិន័យមន្ត្រីមូលដ្ឋាន ឃុំ សង្កាត់ ក្នុងការជំរុញការផ្តល់សេវាជូនប្រជាពលរដ្ឋឱ្យមានប្រសិទ្ធភាព ចំពោះឃុំវល្លិសរ ជាក់ស្តែងក្នុងឆ្នាំ២០២០ កញ្ចប់ថវិកាឃុំមានចំនួន ២៦០លានរៀល ហើយក្នុងឆ្នាំ២០២១ មានកំណើនជិត ៣០០លានរៀល បានធ្វើឱ្យឃុំវល្លិសរ មានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ក្លាយជាឃុំដែលលេចធ្លោជាងគេនៅក្នុងខេត្តកំពង់ស្ពឺ៕

ថ្ងៃព្រហស្បតិ៍ ១១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២